**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង អប់រំ យុវជន និង កីឡា**

**លេខ :** ៧២៩.........**អយក.**សជណ

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ មករា ឆ្នាំ២០១០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**ជម្រាបមក**
**ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពថ្នាក់កណ្តាល**
**គ្រឹះស្ថានសិក្សា និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ៖** ការដាក់ឲ្យប្រើប្រាស់ជាផ្លូវការពុម្ពអក្សរយូនីកូដខ្មែរ និងកម្រងកម្មវិធីកុំព្យូទ័រការិយាល័យភាសាខ្មែរ

**យោង៖** -លិខិតលេខ ២០៦៨លស.អត របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩
-សារាចរណែនាំលេខ ០១ សរណន របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩
-លិខិតលេខ១៩១ អយក.ពអសិ របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨

តតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសជម្រាបជូន ឯកឧត្តម លោកជំទាវ លោក-លោកស្រីប្រធានជ្រាបថា៖ ដើម្បីបង្កលក្ខណៈងាយស្រួល និងឯកភាពគ្នាលើស្តង់ដានៃការប្រើប្រាស់ពុម្ពអក្សរក្នុងកុំព្យូទ័រ (Computer Font) និងបន្លាស់ប្តូរឯកសារកុំព្យូទ័ររវាងអង្គភាពនានាក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាជាមួយស្ថាប័នក្រសួង អាជ្ញាធរនានា នៃរាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់គ្រប់អង្គភាពថ្នាក់កណ្តាល រាជធានី-ខេត្ត ក្រុង-ខណ្ឌ-ស្រុក គ្រឹះស្ថានអប់រំគ្រប់កម្រិតសិក្សាទាំងអស់ ត្រូវប្រើប្រាស់ពុម្ពអក្សរយូនីកូដខ្មែរ (Khmer Unicode) និងកម្រងកម្មវិធីកុំព្យូទ័រការិយាល័យភាសាខ្មែរ (Khmer Office Application – Open Office in Khmer) សម្រាប់ផលិត និងរៀបចំរាល់លិខិតបទដ្ឋានគតិយុត្តិនានា គ្រប់ឯកសាររដ្ឋបាល ឯកសារសិក្សា និងឯកសារស្រាវជ្រាវគ្រប់កម្រិតសិក្សា ។

ក្នុងករណីអង្គភាពរបស់ឯកឧត្តម លោកជំទាវ លោក-លោកស្រី ជួបប្រទះបញ្ហាបច្ចេកទេសក្នុងការដំឡើងកម្មវិធីខាងលើ ឬចង់ទទួលបានជំនួយបច្ចេកទេសនៃរបៀបប្រើប្រាស់ពុម្ពអក្សរយូនីកូដខ្មែរ និងកម្រងកម្មវិធីកុំព្យូទ័រការិយាល័យភាសាខ្មែរ ឬស្នើសុំបន្ថែមសៀវភៅសិក្សាកម្មវិធីកុំព្យូទ័រភាសាខ្មែរ សូមទាក់ទងជាមួយនាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន (ការិយាល័យបច្ចេកវិទ្យាព័ត៌មានអប់រំ) ក្រសួងអប់រំ យុវជន និងកីឡា ឬតាមរយៈទូរស័ព្ទលេខ ០២៣ ២១០ ១៣៤ ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អង្គភាពថ្នាក់កណ្តាល រាជធានី-ខេត្ត គ្រឹះស្ថានអប់រំគ្រប់កម្រិតសិក្សា ត្រូវចាត់ចែងអនុវត្តជាកំហិត និងត្រូវធ្វើការផ្សព្វផ្សាយបន្តតាមអង្គភាពក្រោមឱវាទ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សូមឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលនូវការរាប់អានអំពីខ្ញុំ។

**អ៊ឹម សិទ្ធី**

*ចម្លងជូន៖*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា (NiDA)*
*-ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP)*
*-ក្រុមការងារវិស័យអប់រំ (ESWG)*
*"ដើម្បីជូនជ្រាបជាព័ត៌មាន"*

អាស័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
Email: crsmeys@camnet.com.kh Web Site: www.moeys.gov.kh